ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៥......សហវ.[illegible]

## សារាចរ
## ស្ដីពី
## ការដាក់ឱ្យអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី ១ នៅរដ្ឋបាលក្រុង ស្រុក ឃុំ និង សង្កាត់ដែលនៅសេសសល់

យោងតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ ដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៩, ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៥ និង សេចក្ដីជូនដំណឹងលេខ ០១១ សហវ ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០២១ ស្ដីពីការអនុវត្តចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំ និង បង្កើតប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ រួចរាល់ សម្រាប់ប្រើប្រាស់ជាទំនាក់ទំនងរវាងរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ជាមួយរតនាគាររាជធានី-ខេត្ត ដោយប្រើប្រាស់កម្មវិធីទូរសព្ទឆ្លាតវៃ និង អាចដំណើរការកាន់នៅលើបណ្ដាញអ៊ីនធឺណិត ។ FMIS Portal ជំនាន់ទី១ នេះ បានដាក់ឱ្យប្រើប្រាស់ ២ ជំហានរួចមកហើយ (ជំហានទី១ ខែ ឧសភា ឆ្នាំ ២០២២ និង ជំហានទី២ ខែ មីនា ឆ្នាំ ២០២៣) នៅរដ្ឋបាលក្រុងចំនួន ៦, រដ្ឋបាលស្រុកចំនួន ១៣៧ និង រដ្ឋបាលឃុំចំនួន ៦៣២ រួមទាំងរតនាគាររាជធានី-ខេត្តទាំងអស់ ។ នៅជំហានទី ៣ FMIS Portal នឹងត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការទៅកាន់រដ្ឋបាលក្រុង ស្រុក ឃុំ និង សង្កាត់ដែលនៅសេសសល់ ។

FMIS Portal ជំនាន់ទី១ មានមុខងារគ្របដណ្ដប់លើប្រតិបត្តិការចំណូល និង ចំណាយថវិកា ដូចខាងក្រោម÷

### ១.ប្រតិបត្តិការចំណូលថវិកា

ក. បន្ទាប់ពីការបង់ចំណូលចូលគណនីចរន្តរបស់រតនាគាររាជធានី-ខេត្ត នៅធនាគារពាណិជ្ជដៃគូ រដ្ឋបាលក្រុង ស្រុក ឃុំ និង សង្កាត់ ត្រូវរៀបចំសលាកបត្របង្វែរចំណូលថវិកា និង ឯកសារពាក់ព័ន្ធ ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន រួចស្កេនជាទម្រង់ PDF ដោយចងក្រងជាសំណុំឯកសារទៅតាមប្រភេទនីមួយៗ ដើម្បីដាក់បញ្ចូលទៅក្នុង FMIS Portal បញ្ជូនទៅរតនាគាររាជធានី-ខេត្ត ។ ចំពោះសលាកបត្រ និង ឯកសារពាក់ព័ន្ធជាច្បាប់ដើម ត្រូវរក្សាទុកនៅអង្គភាពដើមសម្រាប់ជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬ សវនកម្មតាមក្រោយ ។

ខ. រតនាគាររាជធានី-ខេត្ត ដែលជាគណនេយ្យករសាធារណៈ នៅពេលទទួលបានសលាកបត្រ និង ឯកសារពាក់ព័ន្ធ តាមរយៈ FMIS Portal ត្រូវពិនិត្យ និង ផ្ទៀងផ្ទាត់អនុលោមភាពនៃនីតិវិធីហិរញ្ញវត្ថុ ។ នៅពេលពិនិត្យឃើញថាមានអនុលោមភាពហើយ រតនាគាររាជធានី-ខេត្ត ត្រូវកត់ត្រា និង អនុម័តក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) រួចត្រូវអនុម័តសំណើសុំលើប្រតិបត្តិការនៅក្នុង

FMIS Portal ជាមួយនឹងការផ្តល់ជូនជាលេខសម្គាល់ប្រតិបត្តិការផ្ទេរការ ដែលទទួលបានពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទៅរដ្ឋបាលក្រុង ស្រុក ឃុំ ឬ សង្កាត់ តាមរយៈ FMIS Portal នេះវិញ ។ ក្នុងករណីពិនិត្យឃើញមានការបង់ចំណូលពីរដ្ឋបាលក្រុង ស្រុក ឃុំ ឬ សង្កាត់ ប៉ុន្តែមិនទាន់ទទួលបានសលាកបត្រនៅក្នុង FMIS Portal យោងតាមប្រកាសឥណទានរបស់ធនាគារ (Credit Advice) រតនាគាររាជធានី-ខេត្ត ត្រូវកត់ត្រាទៅក្នុងគណនីចំណូលបណ្តោះអាសន្នសិន នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ។

គ. ករណីសលាកបត្រ និង ឯកសារពាក់ព័ន្ធ ពុំទាន់មានលក្ខណៈត្រឹមត្រូវ និង មិនអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន រតនាគាររាជធានី-ខេត្តត្រូវស្នើសុំការបញ្ជាក់បន្ថែមពីអាណាប័កនៃរដ្ឋបាលក្រុង ស្រុក ឃុំ និង/ឬ សង្កាត់ ឬ ផ្តល់ឯកសារបន្ថែម ដោយបញ្ជាក់អំពីចំណុចខ្វះខាតតាមរយៈ FMIS Portal ដើម្បីបញ្ជាក់ពីការទទួលខុសត្រូវ ។ ក្នុងករណីចាំបាច់ រតនាគាររាជធានី-ខេត្ត មានសិទ្ធិស្នើសុំការបញ្ជាក់ ឬ ឯកសារច្បាប់ដើមពាក់ព័ន្ធបន្ថែម ។

ឃ. នៅពេលដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានដាក់ឱ្យអនុវត្តដល់រដ្ឋបាលក្រុង ស្រុក ឃុំ និង/ឬ សង្កាត់ណាមួយដែលកំពុងអនុវត្ត FMIS Portal រដ្ឋបាលក្រុង ស្រុក ឃុំ និង/ឬ សង្កាត់ទាំងនោះ នឹងត្រូវផ្លាស់ប្តូរទៅអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) នោះវិញ ។

**២. ប្រតិបត្តិការចំណាយថវិកា**

ក. ក្រោយពីកិច្ចដំណើរការបញ្ជីត្រូវបានបញ្ចប់ រដ្ឋបាលក្រុង ស្រុក ឃុំ និង/ឬ សង្កាត់ ត្រូវរៀបចំបោះផ្សាយអាណត្តិបើកប្រាក់សម្រាប់ទូទាត់រាល់ការចំណាយថវិកាទាំងអស់ ដោយភ្ជាប់ជាមួយលិខិតយុត្តិការចំណាយស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន រួចត្រូវស្កេនជាទម្រង់ PDF ចងក្រងជាសំណុំឯកសារទៅតាមប្រភេទនីមួយៗ និង ដាក់បញ្ចូលទៅក្នុង FMIS Portal ដើម្បីបញ្ជូនទៅរតនាគាររាជធានី-ខេត្ត ។ រីឯ អាណត្តិបើកប្រាក់ និង លិខិតយុត្តិការចំណាយជាច្បាប់ដើម ត្រូវរក្សាទុកនៅអង្គភាពដើមសម្រាប់ជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬ សវនកម្មតាមក្រោយ ។

ខ. រតនាគាររាជធានី-ខេត្ត ដែលជាគណនេយ្យករសាធារណៈ នៅពេលទទួលបានអាណត្តិបើកប្រាក់ និង លិខិតយុត្តិការចំណាយតាមរយៈ FMIS Portal ត្រូវពិនិត្យ និង ផ្ទៀងផ្ទាត់អនុលោមភាពនៃនីតិវិធីហិរញ្ញវត្ថុ ។ នៅពេលពិនិត្យឃើញថាមានអនុលោមភាពហើយ រតនាគាររាជធានី-ខេត្ត ត្រូវកត់ត្រា និង អនុម័តក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) រួចត្រូវអនុម័តសំណើសុំលើប្រតិបត្តិការនៅក្នុង FMIS Portal ជាមួយនឹងការផ្តល់ជូនជាលេខសម្គាល់ប្រតិបត្តិការផ្ទេរការ ដែលទទួលបានពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទៅរដ្ឋបាលក្រុង ស្រុក ឃុំ និង/ឬ សង្កាត់ តាមរយៈ FMIS Portal វិញមុនពេលបើកផ្តល់សាច់ប្រាក់ទៅតាមអាណត្តិបើកប្រាក់ ។

គ. បន្ទាប់ពីបើកផ្តល់សាច់ប្រាក់ទៅតាមអាណត្តិបើកប្រាក់ជូនទៅរដ្ឋបាលក្រុង ស្រុក ឃុំ និង/ឬ សង្កាត់ រតនាគាររាជធានី-ខេត្ត ត្រូវផ្តល់ដំណឹងអំពីការទូទាត់ការបើកសាច់ប្រាក់រួចរាល់ តាមរយៈ FMIS Portal ទៅកាន់ រដ្ឋបាលក្រុង ស្រុក ឃុំ និង/ឬ សង្កាត់ ។

ឃ. ករណីអាណត្តិបើកប្រាក់ និង លិខិតយុត្តិការចំណាយ ពុំទាន់មានលក្ខណៈត្រឹមត្រូវ និង មិនអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន រតនាគាររាជធានី-ខេត្ត ត្រូវស្នើសុំការបញ្ជាក់បន្ថែមពីអាណាប័កនៃរដ្ឋបាលក្រុង ស្រុក ឃុំ និង/ឬ សង្កាត់ ឬ ផ្តល់ឯកសារបន្ថែម ឬ មិនធ្វើការទូទាត់ជូន ដោយបញ្ជាក់អំពីចំណុចខ្វះខាតតាមរយៈ FMIS Portal ដើម្បីបញ្ជាក់ពីការទទួលខុសត្រូវ ។ ក្នុងករណីចាំបាច់ រតនាគាររាជធានី-ខេត្ត មានសិទ្ធិស្នើសុំការបញ្ជាក់ ឬ ឯកសារច្បាប់ដើមពាក់ព័ន្ធបន្ថែម ។

ង. នៅពេលដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្វ័យ (FMIS) ត្រូវបានដាក់ឱ្យអនុវត្តដល់រដ្ឋបាលក្រុង ស្រុក ឃុំ និង/ឬ សង្កាត់ ណាមួយដែលកំពុងអនុវត្ត FMIS Portal រដ្ឋបាលក្រុង ស្រុក ឃុំ និង/ឬ សង្កាត់ ទាំងនោះ នឹងត្រូវផ្លាស់ប្តូរទៅអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្វ័យ (FMIS) នោះវិញ ។

ទទួលបានសារាចរនេះ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត អភិបាលនៃគណៈអភិបាលក្រុង/ស្រុក មេឃុំ និង ចៅសង្កាត់ លោក លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ប្រធានរតនាគាររាជធានី-ខេត្ត និង នាយកទីចាត់ការហិរញ្ញវត្ថុសាលារាជធានី-ខេត្ត ដែលជាក្រុមការងារគាំទ្រការរៀបចំ និង អនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក ឃុំ និង សង្កាត់ មេត្តាជ្រាប និង សម្រួលដល់កិច្ចដំណើរការអនុវត្ត FMIS Portal ដំណាក់កាលទី៣ នេះ ដល់រដ្ឋបាលក្រុង ស្រុក ឃុំ និង សង្កាត់ ដូចមានចែងនៅក្នុងសារាចរនេះ ឱ្យមានប្រសិទ្ធភាព និង ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចេញសារាចរនេះតទៅ ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែបឋមាសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់រដ្ឋបាលរាជធានី-ខេត្ត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត
- រតនាគាររាជធានី-ខេត្ត
- គ្រប់រដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ